ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ ២៧៩ សដណ.សរបា

ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលទូទៅ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទេសចរណ៍សម្រាប់ឆ្នាំ២០១៩

**យោង** : លិខិតលេខ ១០៩៧ មស.ក្រខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងទេសចរណ៍ សូមជម្រាបជូនដំណឹងដល់បេក្ខជន សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលទូទៅ ឱ្យបានជ្រាបថា ក្រសួងទេសចរណ៍នឹងរៀបចំប្រឡងប្រជែងជ្រើសរើសបេក្ខជន សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលទូទៅឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទេសចរណ៍សម្រាប់ឆ្នាំ២០១៩ចំនួន **១៥កន្លែង** ក្នុងប្រភេទក្របខណ្ឌ "**គ**" លើមុខជំនាញមានដូចជា៖ **ទេសចរណ៍, នីតិសាស្ត្រ, វិទ្យាសាស្ត្រកុំព្យូទ័រ, គណនេយ្យ, ភាសាអង់គ្លេស, ភាសាចិន និងមុខជំនាញដែលមានឧបនិស្ស័យទេសចរណ៍** មានដូចខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនកន្លែង | ផ្សេងៗ |
|---|---|---|---|
| ១ | **ទីស្តីការក្រសួងទេសចរណ៍** | ០៥ | |
| ២ | **មន្ទីរទេសចរណ៍រាជធានី ខេត្ត** | ១០ | |
| ២.១ | មន្ទីរទេសចរណ៍រាជធានីភ្នំពេញ | ០២ | |
| ២.២ | មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ | ០៤ | |
| ២.៣ | មន្ទីរទេសចរណ៍ខេត្តកំពត | ០២ | |
| ២.៤ | មន្ទីរទេសចរណ៍ខេត្តកែប | ០១ | |
| ២.៥ | មន្ទីរទេសចរណ៍ខេត្តសៀមរាប | ០១ | |
| **សរុបរួម** | | **១៥** | |

### ក-លក្ខខណ្ឌនៃការជ្រើសរើស

- មានសញ្ជាតិខ្មែរ
- លក្ខខណ្ឌអាយុ៖
  - បេក្ខជនមានសញ្ញាបត្រថ្នាក់**បរិញ្ញាបត្រ** ត្រូវមានអាយុមិនលើសពី **៣៥ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)
  - បេក្ខជនមានសញ្ញាបត្រថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់**ត្រូវមានអាយុមិនលើសពី **៤០ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)
  - ត្រូវបានលើកលែងលក្ខខណ្ឌអាយុចំពោះបេក្ខជនជាមន្ត្រីរាជការស៊ីវិលទូទៅ និងបេក្ខជនដែលមានសញ្ញាបត្រថ្នាក់**បណ្ឌិត**ឡើងទៅ

- បេក្ខជនជាមន្ត្រីរាជការស៊ីវិលទូទៅ ត្រូវមានលិខិតអនុញ្ញាតពីប្រធានក្រសួង ឬស្ថាប័ន
- បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត
- ក្នុងករណីពិនិត្យឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជនប្រឡងជាប់ក៏ដោយ។

## ខ-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំប្រឡង

- **កាលបរិច្ឆេទផ្តល់ពាក្យ និងទទួលពាក្យ៖** ចាប់ពីថ្ងៃទី១៦ **ខែកក្កដា ឆ្នាំ២០១៩ នេះតទៅ** រៀងរាល់ថ្ងៃពេលម៉ោងធ្វើការ
- **កាលបរិច្ឆេទឈប់ទទួលពាក្យ៖** ថ្ងៃទី២៧ **ខែសីហា ឆ្នាំ២០១៩** វេលាម៉ោង **៥:៣០ នាទីល្ងាច**
- បេក្ខជនត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងដោយផ្ទាល់ខ្លួន នៅទីស្តីការក្រសួងទេសចរណ៍ ដែលមានអាសយដ្ឋាន៖ **ដីឡូត៍លេខ ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ** (**នាយកដ្ឋានធនធានមនុស្ស**) និងនៅ**មន្ទីរទេសចរណ៍រាជធានី ខេត្ត ខាងលើ**
- បេក្ខជនដែលមានបំណងដាក់ពាក្យទៅបម្រើការងារនៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវមានទីលំនៅបច្ចុប្បន្នស្ថិតនៅក្នុងរាជធានី ខេត្តនោះ ព្រមទាំងមានការបញ្ជាក់ពីប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត នៅលើពាក្យសុំចុះឈ្មោះប្រឡងជាកំណត់។

## គ-វិញ្ញាសាប្រឡង

- ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ (រយៈពេល **០២ ម៉ោង**)
- ភាសាអង់គ្លេស ឬ ភាសាចិន (រយៈពេល **០១ ម៉ោង៣០នាទី**)

## ឃ-មណ្ឌលប្រឡង និងកាលបរិច្ឆេទ នៃការប្រឡង

ចំពោះមណ្ឌលប្រឡង និងកាលបរិច្ឆេទ នៃការប្រឡង ក្រសួងទេសចរណ៍នឹងធ្វើការជូនដំណឹងនៅពេលក្រោយ។

## ង-សំណុំលិខិតក្នុងការដាក់ពាក្យប្រឡងរួមមាន

| | |
|---|---|
| ១-ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| ២-ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤x៦) | ចំនួន ០១ ច្បាប់ |
| ៣-កិច្ចសន្យាបម្រើការងារ | ចំនួន ០១ ច្បាប់ |
| ៤-សលាកបត្រឯកត្តជន | ចំនួន ០១ ច្បាប់ |
| ៥-បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០១ ច្បាប់ |
| ៦-សេចក្តីថតចម្លងសញ្ញាបត្រ | ចំនួន ០១ ច្បាប់ |
| ៧-សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន ០១ ច្បាប់ |
| ៨-សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន ០១ ច្បាប់ |
| ៩-លិខិតអនុញ្ញាតរបស់ប្រធានក្រសួង ឬស្ថាប័ន(សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ ច្បាប់ |
| ១០-លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់ជាស្ថាពរ) | ចំនួន ០១ ច្បាប់ |
| ១១-លិខិតបញ្ជាក់សុខភាព (ក្រោយពេលប្រឡងជាប់ជាស្ថាពរ) | ចំនួន ០១ ច្បាប់ |

រាល់លិខិតស្នាមពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយខាងលើ ត្រូវមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ។

ចំពោះព័ត៌មានលម្អិតផ្សេងទៀត បេក្ខជនអាចទំនាក់ទំនងសាកសួរនៅនាយកដ្ឋានធនធានមនុស្ស នៃក្រសួងទេសចរណ៍ រៀងរាល់ម៉ោងធ្វើការ ឬតាមទូរស័ព្ទលេខ៖ **០១២ ៥៩៥ ៦៦៦/០៨៦ ៦២២ ៦៩០/ ០១៧ ៥០៨ ៧៩៧/ ០៨៧ ៧៣៧ ៧៨៥** និងមន្ទីរទេសចរណ៍រាជធានី ខេត្តខាងលើ។

***កំណត់សម្គាល់៖ សូមរក្សាសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់។**

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
  «ដើម្បីជូនព្រាប និងជួយផ្សព្វផ្សាយ»
- ឯកសារ កាលប្បវត្តិ